**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

**រវាង**

ក្រុមហ៊ុន ឃ្យូ-ផត អ៊ិនវេសមិន (ខេមបូឌា) ឯ.ក

**ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុមប្រចាំក្រុមហ៊ុន**

នៅថ្ងៃទី ២២ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ០៧និង ៣០នាទីព្រឹក នៅក្នុងរោងចក្រ ឃ្យូ-ផត អ៊ិនវេសមិន (ខេមបូឌា) ឯ.ក មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន នឹង តំណាងកម្មករនិយោជិត។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលអោយសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន១៨៤នាក់ (ស្រី១៥៤នាក់ ប្រុស៣០នាក់) ក្នុងចំនោម កម្មករនិយោជិត សរុបចំនួន១៨៤នាក់ ។ រយះពេល០១ខែ ដោយចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២។ ហើយក្នុងអំឡុងពេលពេលព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលការផ្តល់ជូន របស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ៤០ដុល្លារអាមេរិកក្នុង០១ខែ ។

ប្រាក់ឧបត្ថមក្នុងកំឡុងពេលព្យួរការងារនេះនិងបើកជូនបងប្អូនកម្មករនៅថ្ងៃទី១០នៅខែបន្ទាប់ ។

អង្គប្រជុំបានចប់នៅវេលាម៉ោង ០៩និង៣០នាទី ព្រឹកនាថ្ងៃដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោម ស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន ។

ថ្ងៃចន្ទ័ ០៣កើតខែស្រាពណ៍ ឆ្នាំខាលចត្វាស័ក ព.ស ២៥៦៦

ភ្នំពេញ.ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០២២

**តំណាងកម្មករ និយោជិត** | **នាយកក្រុមហ៊ុន**